https://khmer.voanews.com/a/for-more-than-three-months-over-10-000-workers-protested-over-factory-closed-job-suspended/5 Go
13 captures
19 Sep 2020 - 22 Mar 2024
DEC MAR APR
22
2023 2024 2025
About this capture



សេដ្ឋកិច្ច

# អង្គការសង់ត្រាល់៖ ក្នុងរយៈពេល៣ខែ កម្មករជាង១ម៉ឺននាក់ចេញមុខតវ៉ារឿងបិទរោងចក្រ មិនគោរពច្បាប់ការងារ

០៨ មិថុនា ២០២០

សុិន ណារិន



រូបឯកសារ៖ កម្មកររោងចក្រពាក់ម៉ាស់ការពារកុំឲ្យឆ្លងវីរុសកូរ៉ូណា ខណៈដែលពួកគេដើរចេញពីរោងចក្រដែលពួកគេធ្វើការ ភ្នំពេញ ថ្ងៃសុក្រ ទី២០ ខែមីនា ឆ្នាំ២០២០។ (AP Photo/Heng Sinith)

ភ្នំពេញ — ក្នុងរយៈពេលជាង៣ខែមកនេះ កម្មកររោងចក្រសរុបជាង ១ ម៉ឺននាក់ បានចេញមុខតវ៉ាទាមទារការផ្តល់ប្រាក់ការងារ និងទូទាត់ប្រាក់តាមផ្លូវច្បាប់ក្រោយរោងចក្រប្រកាសព្យួរការងាររបស់កម្មកររួចហើយក៏បិទរោងចក្រតែម្តង។ នេះបើតាមមន្ត្រីសិទ្ធិការងារនៃអង្គការសង់ត្រាល់។

លោក ឃុន ថារ៉ូ មន្ត្រីសម្របសម្រួលផ្នែកការងារនៃមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារនិងសិទ្ធិមនុស្ស ហៅកាត់ថាសង់ត្រាល់ថ្លែងប្រាប់ VOA នៅថ្ងៃច័ន្ទនេះថា អង្គការរបស់លោកបានចងក្រងការតវ៉ារបស់កម្មករដែលរោងចក្ររបស់ពួកគេបិទផលិតកម្ម អំឡុងពេលមានការរាតត្បាតជំងឺកូវីដ។

ក្នុងនោះកម្មករចំនួន ១១.៣២៩ នាក់ មកពីរោងចក្រចំនួន ១៩ បានចេញមុខតវ៉ា។ រោងចក្រទាំងនោះមាននៅភ្នំពេញនៅខេត្តកណ្តាល ខេត្តកំពង់ស្ពឺ និងខេត្តតាកែវ។ លោកថា ចំនួនកម្មករដែលចេញមុខតវ៉ាអាចលើសនេះ ដោយសារអង្គការរបស់លោកមិនបានចងក្រងទូទាំងប្រទេសនិងគ្រប់រោងចក្រនោះទេ។

បើតាមលោក ថារ៉ូ ការទាមទាររបស់កម្មកររួមមានការមិនផ្តល់ប្រាក់អតីតភាពការងារការបញ្ឈប់មិន

ផ្តល់សំណងការព្យួរការងារកម្មករ តែក្រោយមកបញ្ឈប់តែម្តងនិងការមិនផ្តល់ប្រាក់ខែចុងក្រោយដែលពួកគេបំពេញការងារជាដើម។

លោកថ្លែងប្រាប់ VOA នៅថ្ងៃច័ន្ទនេះ៖ «យើងគិតថាបើសិនជាស្ថានភាពហ្នឹង វាកាន់តែអូសបន្លាយយូរទៅ វាកាន់តែមានរោងចក្រផ្សេងៗទៀតហ្នឹងប្រឈមទៅនឹងការបិទទ្វារ ឬក៏ការបិទដោយមិនមានការជូនដំណឹង ឬក៏មិនមានការទូទាត់ឲ្យត្រឹមត្រូវទៅតាមផ្លូវច្បាប់ជូនកម្មករនិយោជិត។ ហើយនៅក្នុងលក្ខខណ្ឌហ្នឹងហើយ ដែលយើងមើលឃើញថា បញ្ហាប្រឈមរបស់កម្មករគាត់នឹងអាចបាត់បង់នូវអត្ថប្រយោជន៍ការគាំពារផ្នែកច្បាប់នូវសំណងនៃការទូទាត់ដែលកម្មករគាត់ត្រូវទទួលបានក្នុងករណីដែលក្រុមហ៊ុនរោងចក្រហ្នឹងត្រូវបានបិទទ្វារ»។

សង្គ្រាមរវាងអ៊ីស្រាអែលនិង ហាម៉ាស់

លោក ឃុន ថារ៉ូ បារម្ភថានឹងមានការតវ៉ាបន្ថែមទៀត ប្រសិនបើស្ថានភាពនេ
លោកបន្ថែមថា មានតែក្រសួងការងារទេដែលជាអ្នកដោះស្រាយបញ្ហានេះប
របស់កម្មករ។

លោកមានប្រសាសន៍ថា៖ «ខ្ញុំគិតថា ស្ថានភាពហ្នឹងអ្នកទទួលខុសត្រូវគឺមានតែម្ចាស់ក្រុមហ៊ុនហ្នឹងហើយ។ ហើយកាលណា គាត់រត់ចេញពីកាតព្វកិច្ចរបស់គាត់មិនដោះស្រាយ អាហ្នឹងមានតែរដ្ឋហ្នឹងហើយដែលត្រូវមានវិធានការផ្នែកច្បាប់ នៅក្នុងការចាប់បង្ខំនិយោជកហ្នឹង ឲ្យគាត់ទទួលខុសត្រូវទៅតាមផ្លូវច្បាប់»។

បើតាមលោក ឃុន ថារ៉ូ រោងចក្រនោះមានដូចជា New Best Global Textile កំពង់ស្ពឺ រោងចក្រCrystal Martin ខេត្តកណ្តាលរោងចក្រ Propitious Cambodia ខេត្តកណ្តាល និងរោងចក្រChea Sinat Garment Factory ភ្នំពេញជាដើម។

កម្មករម្នាក់ដែលធ្វើការនៅរោងចក្រ New Best Global Textile គឺអ្នកស្រី ព្រហ្ម តុលា មានប្រសាសន៍ថា អ្នកស្រីនិងកម្មករជាង ៧០០ នាក់ទៀត អត់មានការងារធ្វើ តាំងពីថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២០ ដោយពីដំបូងឡើយរោងចក្រថា ព្យួរការងារនិងក្រោយមកថាបិទរោងចក្រតែម្តង។

អ្នកស្រី តុលា អាយុ ៣៦ ឆ្នាំ មានកូន ២ នាក់ និងជាប់បំណុលគេផងនោះ មានប្រសាសន៍ថា អ្នកស្រីមិនបានទទួលប្រាក់ខែចុងក្រោយ ៨ ថ្ងៃ ប្រាក់ឧបត្ថម្ភដែលសន្យាដោយរដ្ឋាភិបាលនិងរោងចក្រ ប្រាក់បំណាច់ការងារ ប្រាក់អត្ថប្រយោជន៍ផ្សេងៗ និងសំណងការបិទរោងចក្រមិនជូនដំណឹងជាដើមនោះទេ។

អ្នកស្រី ព្រហ្ម តុលា ដែលជាអតីតប្រធានផ្នែកត្រួតពិនិត្យខោអាវនៅរោងចក្រហើយ ដែលទទួលបានប្រាក់ខែប្រមាណ ៣៧០ ដុល្លារក្នុងមួយខែនោះ បានមានប្រសាសន៍ថា អ្នកស្រីកំពុងបារម្ភរឿងជំពាក់បំណុលធនាគារស្ថាបនា ដែលអ្នកស្រីត្រូវបង់មួយខែជាង ៦០០ ដុល្លារ។ ពីដើមឡើយ អ្នកស្រីយល់ថា អ្នកស្រីមានលទ្ធភាពបង់រួច ដោយសារមានចំណូលពីស្វាមីលក់ដូរចាប់ហួយ។

អ្នកស្រីមានប្រសាសន៍ថា៖ «ជីវភាពពិបាកជាងមុនឆ្ងាយ ទីមួយ ត្រូវការលុយបង់ធនាគារ ទីពីរ លុយទិញទឹកដោះគោឲ្យកូន ហើយលុយត្រូវការចាយប្រចាំថ្ងៃ។ ពិបាកខ្លាំងដែរហ្នឹង»។

លោក ហេង សួរ អ្នកនាំពាក្យក្រសួងការងារមានប្រសាសន៍ថា មន្ត្រីក្រសួងទាំងនៅកម្រិតក្រសួងនិងមន្ទីរតាមខេត្តបានចុះសម្របសម្រួល និងដោះស្រាយវិវាទរបស់កម្មករ និងថៅកែរោងចក្រទៅតាមករណីនីមួយៗ។

លោកមានប្រសាសន៍ថា៖ «ករណីខ្លះគឺជារឿងដែលមានចែងនៅក្នុងច្បាប់ត្រូវទទួលបាន ប៉ុន្តែជាក់ស្តែងនិយោជកមិនមានថវិកាគ្រប់គ្រាន់ ដើម្បីបើកផ្តល់ជូនកម្មករ ដូច្នេះយើងសម្របសម្រួលឲ្យមានការកំណត់ថ្ងៃឲ្យបានច្បាស់លាស់។ ក្នុងករណីមិនមានលទ្ធភាពជាអចិន្ត្រៃយ៍ គឺត្រូវអនុវត្តទៅតាមច្បាប់ក្ស័យធនបិទទ្វាររោងចក្រ»។

កាលពីសប្តាហ៍មុន ក្រសួងការងារបានសម្រេចលើកពេលបើកប្រាក់បំណាច់អតីតភាពការងារ

សម្រាប់កម្មករទៅឆ្នាំ ២០២១ ក្នុងគោលបំណងជួយដល់រោងចក្រដែលរងផលប៉ះពាល់ធ្ងន់ធ្ងរពីការរាលដាលជំងឺកូវីដ១៩។

លោក ខេន លូ អគ្គលេខាធិការសមាគមរោងចក្រកាត់ដេរកម្ពុជា ហៅកាត់ថា GMAC មានប្រសាសន៍ថា កម្មករដែលមានបញ្ហាអាចប្តឹងទៅក្រសួងការងារ ដែលលោកថា ក្រសួងអនុវត្តទៅតាមច្បាប់។ លោកបញ្ជាក់ថា លោកមិនមានព័ត៌មានថា តើមានរោងចក្រដែលមិនគោរពតាមច្បាប់ការងារដូចការលើកឡើងរបស់កម្មករ ឬយ៉ាងណានោះទេ។

លោកមានប្រសាសន៍ថា៖ «ខ្ញុំអត់ដឹងថារោងចក្រណា (ដែលអត់គោរពច្បាប់) ប៉ុន្តែទោះបីយ៉ាងណាក៏ដោយពិបាកយ៉ាងម៉េច បើមានរោងចក្រក្ស័យធន់ អាហ្នឹងធ្វើតាមនីតិវិធីក្ស័យធន់។ឧទាហរណ៍យកទ្រព្យសម្បត្តិរោងចក្រទៅលក់ លក់ហើយសល់លុយប៉ុន្មានសងទៅកម្មករ។ ហើយខ្ញុំអត់ដឹងតួលេខសង់គ្រាល់បានមកពីណាមួយម៉ឺនជាង។ ខ្ញុំអត់ដឹងទេ»។

បើតាមលោក ខេន លូ គិតត្រឹមសប្តាហ៍មុន រោងចក្រចំនួន ២៥៩ ត្រូវបានព្យួរដំណើរការ ព្រោះមិនមានការបញ្ជាទិញពីក្រៅប្រទេស ដោយសារការរាលដាលជំងឺកូវីដ។ លោកថា ការព្យួររោងចក្រទាំងនោះធ្វើឲ្យកម្មករជាង ១៣ ម៉ឺននាក់ ត្រូវព្យួរការងារ។

ចាប់តាំងពីរោងចក្រព្យួរការងារកម្មករ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានលើកឡើងថារោងចក្រផ្តល់ប្រាក់ ៣០ ដុល្លារក្នុងមួយខែឲ្យកម្មករ។ ចំណែករដ្ឋាភិបាលថា ផ្តល់ឲ្យ ៤០ ដុល្លារ។ ប៉ុន្តែសហជីពលើកឡើងថា កម្មករមួយចំនួនមិនទទួលបានប្រាក់ឧបត្ថម្ភនោះទេ។

វិស័យកាត់ដេរសម្លៀកបំពាក់និងស្បែកជើង គឺជាក្បាលម៉ាស៊ីននៃការនាំចេញធំបំផុតលំដាប់ទីមួយរបស់កម្ពុជា។ វិស័យនេះបានស្រូបយកកម្លាំងពលកម្មប្រមាណជា ៨០ ម៉ឺននាក់ ដែលភាគច្រើនគឺជាប្រជាពលរដ្ឋមកពីបណ្តាខេត្ត និងជនបទ៕

## អត្ថបទទាក់ទង

- ការតវ៉ាប្រឆាំងការរើសអើងជាតិសាសន៍បានធ្វើឡើងនៅជុំវិញពិភពលោក
- ខ្មែរអាមេរិកាំងផ្តល់តម្លៃចំពោះសេរីភាពនិងច្បាប់នៅអាមេរិក ទោះមានការរំជើបរំជួល
- អង្គការមនុស្សធម៌៖ ពួកគេអាចខ្វះលទ្ធភាពជួយ បើការឆ្លងជំងឺកូវីដ១៩ ក្នុងជំរំជនភៀសខ្លួន Rohingya រីករាលដាលកាន់តែខ្លាំង
- ស្ថានទូតថៃថា មិនមានព័ត៌មានអំពីសកម្មជនថៃបាត់ខ្លួននោះទេ ខណៈកម្ពុជាថាមិនស៊ើបអង្កេតការបាត់ខ្លួននេះ

## ផតខាសថ៍ថ្មីបំផុត

Latest episode

## កម្ពុជាសម្លឹងទៅមុខ - Envision Cambodia

Subscribe

## វីដេអូថ្មីៗបំផុត




អង្គការ Golos ហៅការបោះឆ្នោតប្រធានាធិបតីរុស្ស៊ីថាជា«ការធ្វើត្រាប់»

## ព័ត៌មានថ្មីៗបំផុត

អង្គការយូនីសេហ្វបើកយុទ្ធនាការការពារកុមារពីការរំលោភបំពានផ្លូវភេទតាមអនឡាញ

ភរិយាសកម្មជនគណបក្សកម្លាំងជាតិស្នើសុំដោះលែងស្វាមីដែលរងបទចោទញុះញង់

គ្រាប់បែកអត្តឃាតបានផ្ទុះនៅមូលដ្ឋាននយោបាយពួកតាលីបង់នាប៉ែកខាងត្បូងអាហ្វហ្គានីស្ថាន